UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា
# លោកសាស្ត្រាចារ្យ ស៊ូយ៉ា ស៊ូប៊ីឌី

ភ្នំពេញថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០

ខ្ញុំជិតបញ្ចប់ដំណើរបេសកកម្មរយៈពេលពីរសប្តាហ៍របស់ខ្ញុំនៅកម្ពុជាហើយ ដើម្បីតាមឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្ស និងដើម្បីចូលរួមពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យនេះ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ផ្នែកសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធឯទៀត ដើម្បីធ្វើឲ្យកាន់តែប្រសើរដល់របបនៃការការពារ និងការលើកស្ទួយសិទ្ធិមនុស្ស។ ទោះបីជាស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា នៅមិនទាន់បំពេញបានគ្រប់គ្រាន់តាមសេចក្តីតម្រូវក្នុងបទដ្ឋានអន្តរជាតិក្តី ក៏ខ្ញុំមានការពេញចិត្តចំពោះការរីកចំរើនដែលប្រទេសកម្ពុជាទទួលបានក្នុងវិស័យជាច្រើន ចាប់ពីពេលដែលខ្ញុំបំពេញទស្សនកិច្ច កាលពីពេលកន្លងមកក្នុងខែមិថុនា ឆ្នាំ២០០៩ និងដោយឃើញអំពីឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការធ្វើការជាមួយខ្ញុំ ដើម្បីកំណត់អំពីបញ្ហា និងដោះស្រាយបញ្ហានោះទាំងអស់គ្នា។ ឧទាហរណ៍ នៃវិស័យរីកចំរើនទាំងនេះ រួមមានការពង្រឹងក្របខ័ណ្ឌច្បាប់ ដើម្បីគ្រប់គ្រងបញ្ហានៃការបណ្តេញចេញប្រជាពលរដ្ឋមួយចំនួននៅទីក្រុង និងការតាំងលំនៅថ្មី ការបញ្ចប់រឿងក្តីទីមួយនៅសាលាក្តីខ្មែរក្រហម និងការរីកចំរើនល្អៗក្នុងការស៊ើបអង្កេតករណីជាបន្តបន្ទាប់ កិច្ចខិតខំប្រឹងប្រែងបន្តទៀតក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធពន្ធនាគារ ការអនុម័តក្រមព្រហ្មទណ្ឌ និងរបបសំរាប់ការធ្វើបាតុកម្មជាសាធារណៈដែលមានការកែលំអ ។

ខ្ញុំមានបុព្វសិទ្ធិជួបប្រជុំជាមួយឯកឧត្តមនាយករដ្ឋមន្ត្រី លោក ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់មួយចំនួននៃរដ្ឋាភិបាល មេដឹកនាំគណបក្សនយោបាយនានាក្នុងរដ្ឋសភា ប្រធាន និងសមាជិកស្ថាប័ននានានៃរដ្ឋធម្មនុញ្ញ ឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតនានានៅរាជធានីភ្នំពេញ និងតំណាងសង្គមស៊ីវិល ហើយខ្ញុំមានសេចក្តីសោមនស្សរីករាយ ចំពោះការបញ្ជាក់អះអាងអំពីកិច្ចសហប្រតិបត្តិការដែលខ្ញុំបានទទួលពីពួកគេ ។

រដ្ឋាភិបាលបានទទួលយកការស្នើឡើងមួយចំនួន រាប់ទាំងការបង្កើតគោលការណ៍គតិយុត្តិថ្នាក់ជាតិស្តីពីការបណ្តេញចេញពីដីធ្លី ការធ្វើឲ្យដំណើរការធ្វើច្បាប់មានតម្លាភាពថែមទៀត តាមរយៈការចែករំលែកសេចក្តីព្រាងច្បាប់ដែលមានផលប៉ះពាល់លើបញ្ហាសិទ្ធិមនុស្សជាមួយសហាគមន៍ទូលំទូលាយច្រើនថែមទៀត និងបង្កើតឲ្យមានវេទិការដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីពង្រឹងបរិយាកាសនៃកិច្ចសហប្រតិបត្តិការ សំដៅពង្រឹងលិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស នៅក្នុង

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ប្រទេស។ រដ្ឋាភិបាល បាននិងកំពុងចូលរួមកាន់តែសកម្មឡើងថែមទៀត ជាមួយស្ថាប័ននានាខាងសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងការកំណត់បញ្ហាដែលត្រូវការឲ្យមានការដោះស្រាយនៅក្នុងប្រទេស។ ខ្ញុំសង្ឃឹមថា រដ្ឋាភិបាលនឹងបោះជំហានទៅមុខ ជាមួយនឹងដំណើរការធ្វើសេចក្តីសំរេចដោយមានការដាក់បញ្ចូល មានការចូលរួម និងមានតម្លាភាពថែមទៀត លើបញ្ហាទាំងឡាយដែលមានផលប៉ះពាល់ផ្ទាល់ទៅលើសិទ្ធិមនុស្សរបស់ប្រជាជន។ បញ្ហាប្រឈមគឺអនុវត្តដោយជាក់ស្តែងនូវការសន្យាដែលរដ្ឋាភិបាលបានធ្វើនៅក្នុងរបាយការណ៍របស់ខ្លួន ដាក់ជូនស្ថាប័ននានារបស់អង្គការសហប្រជាជាតិ និងស្ថាប័នសន្ធិសញ្ញានានា។

បន្ទាប់ពីបញ្ចប់ទស្សនកិច្ចលើកទីមួយរបស់ខ្ញុំ នៅកម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០០៩ ដែលជាបេសកកម្មមួយ ដែលផ្តោតជាសំខាន់លើការស្វែងយល់អំពីស្ថានការណ៍ ខ្ញុំបានឈានជើងចូលក្នុងដំណាក់កាលថ្មីមួយ ដែលក្នុងនោះខ្ញុំកំពុងពិនិត្យមើលលើការងារ និងប្រសិទ្ធិភាពរបស់ស្ថាប័នរដ្ឋទាំងឡាយដែលទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារនីតិរដ្ឋ និងដោះស្រាយបញ្ហាសិទ្ធិមនុស្សរបស់ប្រជាជនកម្ពុជា។ ដោយសារលិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សវិញឆ្លងចូលគ្នាតែមួយ អ្វីដែលមានក្នុងចិត្តរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការអនុវត្តន៍គោលការណ៍បែងចែកអំណាច និងការពិនិត្យតុល្យភាពអំណាចទាំងនោះ មានជាប់ជំពាក់យ៉ាងជ្រៅទៅនឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សដោយស្ថាប័នរដ្ឋ។ ឯករាជ្យភាពតុលាការ និងលទ្ធភាពរបស់ប្រព័ន្ធនេះ ក្នុងការធានាឲ្យមានការគោរព ការជឿជាក់ និងជំនឿទុកចិត្តរបស់ប្រជាជន គឺជាប្រការមួយសំខាន់ខ្លាំងណាស់សំរាប់សង្គមកម្ពុជាដែលកំពុងស្ថិតក្នុងដំណើរការនៃអន្តរកាល ពីកេរ្តិ៍តំណែលនៃអតីតកាលដ៏សោកនាដកម្ម។ ហេតុដូចនេះ ខ្ញុំបានស្នើឲ្យមានការបង្កើនថវិកាដល់វិស័យយុត្តិធម៌ថែមទៀត និងការអនុម័តដោយគ្មានការពន្យាពេលតទៅទៀតនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ និងច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលជាជំហានដ៏សំខាន់ ដើម្បីសំរេចគោលដៅនេះ។

អំណាចនីតិប្រតិបត្តិរបស់រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ ក្នុងការដឹកនាំប្រជាជាតិឆ្ពោះទៅកាន់ស្ថានភាពមួយដែលបុគ្គលម្នាក់ៗ អាចកំណត់ជាអតិបរមានូវសក្តានុពលរបស់ខ្លួននៅក្នុងក្របខ័ណ្ឌលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែអំណាចនីតិប្រតិបត្តិ ត្រូវតែមានតុល្យភាពជាមួយនឹងអំណាចនីតិបញ្ញត្តិ និងអំណាចឯករាជ្យរបស់តុលាការ ក្រោមដំបូលនីតិរដ្ឋ។ អំណាចនីតិប្រតិបត្តិ គួរតែធ្វើជាគំរូល្អមួយ ដោយបង្ហាញនូវការអនុគ្រោះដ៏ធំធេងដល់ប្រព័ន្ធពហុនិយមប្រជាធិបតេយ្យ។ ដោយសារតែសភាគឺជាព្រលឹងនៃលទ្ធិប្រជាធិបតេយ្យដែលមានសារៈសំខាន់ស្មើគ្នា តំរូវឲ្យមានរដ្ឋសភាមួយដែលដំណើរការត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាព មានសមត្ថភាពតំណាងឲ្យបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ហើយធ្វើឲ្យអំណាចនីតិប្រតិបត្តិមានការទទួលខុសត្រូវ។ ប្រទេសកម្ពុជាមានភាពជឿនលឿនក្នុងការបង្កើតស្ថាប័ននានា ដើម្បីលើកស្ទួយ និងការពារនីតិរដ្ឋ លទ្ធិប្រជាធិប-តេយ្យ និងសិទ្ធិមនុស្ស។ ក៏ប៉ុន្តែ មានការបារម្ភមួយចំនួនពីដំណើរប្រព្រឹត្តទៅនៃស្ថាប័នទាំងនេះឲ្យមានប្រសិទ្ធិភាពជាក់លាក់ និងមិនលំអៀងតាមតែអាចធ្វើបាន។ ការបង្កើតស្ថាប័នគឺជាបញ្ហាមួយ តែដំណើរការដ៏ត្រឹមត្រូវរបស់ស្ថាប័នទាំងនោះ គឺជាបញ្ហាមួយទៀត។

វាមានសារៈសំខាន់ណាស់សំរាប់សភា ដែលជាទូទៅ គឺជាសភាជជែកពិភាក្សាលើបញ្ហាសំខាន់ៗរបស់ជាតិ ធ្វើឲ្យសមាជិកទាំងអស់របស់ខ្លួន សំដែងនូវទស្សនៈរបស់ពួកគេដោយសេរី

និងចូលរួមដោយពេញលេញនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយមិនគិតពីគណបក្សនយោបាយរបស់គេ ប្រសិនជាមិនចង់ឲ្យមើលឃើញថាវាគ្រាន់តែជាកន្លែងមួយសំរាប់ប្រថាប់ត្រានោះ។ ស្ថាប័ននេះ ក៏ត្រូវមានអំណាចក្នុងការកែប្រែ និងធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ផងដែរ ទោះជាការកែប្រែទាំងនោះផ្ទុយពីគោលបំណងរបស់អំណាចនីតិប្រតិបត្តិក៏ដោយ។ គោលការណ៍ប្រជាធិបតេយ្យ ទាមទារឲ្យអ្នកភាគច្រើន គោរពអ្នកភាគតិច ក្នុងការធ្វើសេចក្តីសំរេច។ បញ្ហាប្រឈមគឺមិនត្រឹមតែការអនុវត្តតាមច្បាប់ដែលមានជាធរមាននោះទេ ប៉ុន្តែត្រូវធ្វើឲ្យច្បាប់នោះមានលក្ខណៈប្រជាធិបតេយ្យ និងមានលក្ខណៈសមស្របថែមទៀតចំពោះការសំដែងពីសំលេងចំរុះ និងការអាស្រ័យបាននូវសិទ្ធិ និងសេរីភាពដោយប្រជាជនកម្ពុជា។

សិទ្ធិដីធ្លី និងផ្ទះសំបែង សេរីភាពនៃការសំដែងមតិ និងឯករាជ្យតុលាការ គឺជាបញ្ហាមួយចំនួននៃបញ្ហាស្នូល ដែលបានថ្លែងមកកាន់ខ្ញុំ ដោយតំណាងសង្គមស៊ីវិល។ ខ្ញុំយល់ថាផ្នែកជាច្រើននៃបញ្ហាទាំងនេះ ក៏មានជាប់ពាក់ព័ន្ធផងដែរនឹងឯករាជ្យភាព តម្លាភាព និងគណនេយ្យភាព នៃស្ថាប័នរបស់រដ្ឋដែលមានអាណត្តិការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ បញ្ហាប្រឈម គឺការបំផ្លែងកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជា មិនត្រឹមតែទៅក្នុងច្បាប់ជាតិនោះទេ តែទៅក្នុងការអនុវត្តន៍ជាក់ស្តែងផង ដើម្បីពង្រឹងវប្បធម៌ប្រជាធិបតេយ្យ និងការអនុគ្រោះគ្នា ដូចដែលបានតំរូវ ឲ្យដឹកនាំប្រទេសឆ្ពោះទៅកាន់សន្តិភាពជានិរន្ត កាន់តែសំបូររុងរឿង និងឯកភាពជាតិ។ ដោយការចងចាំគោលការណ៍ទាំងនេះក្នុងចិត្ត ខ្ញុំបានរៀបចំផែនការជំហានបន្ទាប់ នៃការងាររបស់ខ្ញុំនៅកម្ពុជា ហើយខ្ញុំសង្ឃឹមថា នឹងទទួលបានកិច្ចសហប្រតិបត្តិការពេញលេញពីរាជរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិនៅកម្ពុជា។

ខ្ញុំរីករាយណាស់ ចំពោះឱកាសដែលខ្ញុំមាន នៅក្នុងដំណើរទស្សនកិច្ចនេះ ដើម្បីបង្ហាញអំពីបំណងប្រាថ្នារបស់ខ្ញុំ ក្នុងការចូលរួមពិភាក្សាក្នុងន័យស្ថាបនាជាមួយរាជរដ្ឋាភិបាលកម្ពុជានិងដើម្បីផ្តល់ការជួយឧបត្ថម្ភរបស់ខ្ញុំ ក្នុងការជួយដោះស្រាយបញ្ហាមួយចំនួនដែលជាកង្វល់ខាងសិទ្ធិមនុស្សដែលប្រទេសនេះកំពុងជួបប្រទះ។ ខ្ញុំសូមអរគុណដល់រាជរដ្ឋាភិបាល ចំពោះការពិភាក្សាលើបញ្ហាដែលជាកង្វល់ដោយចំហ គ្មានការលាក់លៀម និងស្នើឲ្យខ្ញុំ ជួយគាត់ដោះស្រាយបញ្ហាដែលជាចំណុចខ្វះខាត ដែលនៅតែមាន ក្នុងការគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យនៃប្រទេស និងក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។ ឆ្លៀតឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណ ដោយស្មោះសរចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី លោក ហ៊ុន សែន និងរដ្ឋមន្ត្រីជាន់ខ្ពស់ដទៃទៀត អង្គទូត និងដៃគូពាក់ព័ន្ធដទៃទៀតនៅក្នុងសង្គម រួមទាំងអ្នកទាំងឡាយ ធ្វើការនៅក្នុងប្រព័ន្ធសារព័ត៌មាន និងផ្នែកអង្គការក្រៅរដ្ឋាភិបាល ចំពោះកិច្ចស្វាគមន៍ និងកិច្ចសហប្រតិបត្តិរបស់ឯកឧត្តម លោក លោកស្រី។ ជាចុងបញ្ចប់ ខ្ញុំក៏សូមថ្លែងអំណរគុណដោយស្មោះ ដល់បុគ្គលិកជាតិ និងអន្តរជាតិ ដែលធ្វើការឲ្យការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាចំពោះកិច្ចស្វាគមន៍ និងការគាំទ្ររបស់ពួកគេ ដល់ដំណើរទស្សនកិច្ចរបស់ខ្ញុំ ៕